RISE

Reimagining Industry to Support Equality

Center for Inclusive Growth

# ការកែលម្អសុខភាពហិរញ្ញវត្ថុក្នុង វិស័យកាត់ដេរនៅកម្ពុជា តាមរយៈ ការបើកប្រាក់ឈ្នួលតាមឌីជីថល ប្រកបដោយការទទួលខុសត្រូវ៖ អត្ថប្រយោជន៍សម្រាប់ស្ត្រី និងអាជីវកម្ម

ខែតុលា ឆ្នាំ ២០២៣



# សេចក្តីផ្តើម

ឧស្សាហកម្មកាត់ដេរនៅកម្ពុជាបានផ្តល់ឱ្យកម្មករប្រមាណ១លាននាក់បានទទួលការងារផ្លូវការ ក្នុងនោះ៨០%ជាស្ត្រី។[១] ខណៈពេលដែលការងារទាំងនេះបានផ្តល់ប្រាក់ចំណូលទៀងទាត់ និងមានប្រាក់ឈ្នួលអប្បបរមា ហើយជារឿយៗត្រូវបានបើកជាសាច់ប្រាក់សុទ្ធ។ ទាំងនេះធ្វើឱ្យកម្មករ ជាពិសេសកម្មការនីពិបាកក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេ។ កម្មករកាត់ដេរជាច្រើននាក់មិនទាន់ចេះប្រើប្រាស់សេវាកម្មធនាគារទេ គឺមានតែ ៣៣% នៃមនុស្សពេញវ័យនៅក្នុងប្រទេសកម្ពុជាដែលមានគណនីក្នុងគ្រឹះស្ថានហិរញ្ញវត្ថុ ពួកគេមានដែនកំណត់លទ្ធភាពក្នុងការសន្សំលុយ[២] ព្រមទាំងមានអត្រាខ្ពស់ក្នុងការជំពាក់បំណុលគេ [៣,៤]។

សន្ទុះនៃការបើកប្រាក់ឈ្នួលឌីជីថលនៅក្នុងប្រទេសកម្ពុជា បានផ្តល់ចំណុចរួមមួយដែលធ្វើអោយសុខភាពហិរញ្ញវត្ថុរបស់កម្មករកាត់ដេរមានភាពប្រសើរឡើង។[៥,៦] ខណៈពេលដែលរោងចក្រជាច្រើនបានធ្វើការផ្លាស់ប្តូរទៅអនុវត្តការបើកប្រាក់ឈ្នួលឌីជីថលក៏ដោយ វាត្រូវបានគេប៉ាន់ប្រមាណថានៅប្រហែល ៥០% នៃរោងចក្រកាត់ដេរទៀតនៅតែបន្តបើកប្រាក់ខែដល់កម្មករជាសាច់ប្រាក់។[៧] ការធ្វើបែបនេះ គឺគ្មានប្រសិទ្ធភាព និងប្រថុយប្រថានសម្រាប់និយោជក វាក៏មិនផ្តល់សិទ្ធិអំណាចដល់កម្មករ ជាពិសេសស្ត្រី ដោយសារពួកគេមានការពិបាកក្នុងការគ្រប់គ្រងលើប្រាក់ខែរបស់ពួកគេ។ នៅកន្លែងការងារមួយចំនួនដែលបានបើកប្រាក់ឈ្នួលបែបឌីជីថលរួចហើយ កម្មករនៅតែត្រូវការការគាំទ្រ ការចង្អុលបង្ហាញ ដើម្បីអាចប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ពីគណនីបៀវត្សរ៍របស់ពួកគេ បើមិនដូច្នេះទេ ពួកគេនឹងដកប្រាក់ ១០០% នៃប្រាក់ខែនៅថ្ងៃបើកប្រាក់ខែមិនខាន។[៨]

នៅកម្ពុជា RISE និង Mastercard Center for Inclusive Growth បានចាប់ដៃគូជាមួយគ្នាតាំងពីឆ្នាំ ២០១៩ ដើម្បីគាំទ្រ និងពង្រីកទំហំការបើកប្រាក់ខែដោយផ្អែកលើយេនឌ័រក្នុងវិស័យកាត់ដេរ។ តាមរយៈភាពជាដៃគូ និយោជកទទួលបានការណែនាំ និងដំបូន្មានលើការធ្វើផែនការ និងធ្វើការគណនាប្រាក់បៀវត្សរ៍របស់ពួកគេតាមបែបឌីជីថល ដោយផ្អែកលើតម្រូវការចាំបាច់របស់កម្មការនី។

ការកសាងសមត្ថភាពហិរញ្ញវត្ថុសម្រាប់កម្មករ ជាពិសេសស្ត្រី គឺជាផ្នែកសំខាន់មួយនៃការបើកប្រាក់ឈ្នួលឌីជីថល ដើម្បីឱ្យពួកគេអាចមានចំណេះដឹង និងទំនុកចិត្តក្នុងការប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ពីគណនីប្រាក់បៀវត្សរ៍ថ្មីរបស់ពួកគេ។[៩,១០] តាមរយៈកម្មវិធី RISE Transform Financial Health កម្មករ និយោជិកទទួលបានការបណ្តុះបណ្តាលអំពីយេនឌ័រ រួមទាំងផ្នែកបច្ចេកទេសនៃរបៀបប្រើប្រាស់គណនីប្រាក់បៀវត្សរ៍ថ្មីរបស់ពួកគេ និងសេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធ ព្រមទាំងមេរៀនស្តីពីការធ្វើផែនការហិរញ្ញវត្ថុ ការសន្សំថវិកា និងការពិភាក្សាអំពីហិរញ្ញវត្ថុជាមួយគ្រួសាររបស់ពួកគេ ដែលត្រូវបានបង្កើតឡើងដើម្បីជួយពួកគេក្នុងការគ្រប់គ្រងប្រាក់ឈ្នួលរបស់ពួកគេ ដោយកសាងឯករាជ្យភាព និងភាពយូរអង្វែងនៅក្នុងដំណើរការនៃការអនុវត្តប្រាក់ឈ្នួលឌីជីថល។

របាយការណ៍នេះបង្ហាញពីលទ្ធផល[១១] ពីការគាំទ្រដល់រោងចក្រកាត់ដេរចំនួន ១៧ នៅកម្ពុជាដែលមានកម្មករជាង ២៥,000 នាក់ (ស្ត្រី ៨៥%) ជាមួយនឹងការប្រើប្រាស់ប្រាក់ឈ្នួលឌីជីថល និងសម្រួលឱ្យកម្មករអាចចូលប្រើប្រាស់ និងទទួលបានអត្ថប្រយោជន៍ពីគណនីរបស់ពួកគេ។ អត្ថប្រយោជន៍បានបង្ហាញថា៖

- មានការកើនឡើង ៥៤ ភាគរយនៃកម្មករ (បុរស និងស្ត្រី) ប្រើប្រាស់គណនីប្រាក់ចល័ត រួមបញ្ចូលទាំងការទូទាត់វិក្កយបត្រ ការផ្ញើប្រាក់បញ្ញើ បញ្ចូលលុយទូរស័ព្ទ និងបង់វិក្កយបត្រ។
- មានការកើនឡើង ៣៨ ភាគរយនៃស្ត្រីសន្សំប្រាក់ជាប្រចាំ រួមបញ្ចូលទាំងការចំណាយដែលរំពឹងទុក (ដូចជាវិក័យប័ត្រថ្នាំព្យាបាល របស់របរប្រើប្រាស់ក្នុងផ្ទះ) សម្រាប់គ្រាអាសន្ន និងទិញដី។
- មានការកើនឡើង ២៥ ភាគរយនៃស្ត្រីដែលរាយការណ៍ពីទំនុកចិត្តក្នុងការគ្រប់គ្រងភាពអាសន្នផ្នែកហិរញ្ញវត្ថុ។
- មានការកាត់បន្ថយចំនួន ៨៤ ភាគរយនៃការចំណាយលើផ្នែករដ្ឋបាលដែលសំដៅដល់ការរៀបចំ និងការចែកបញ្ជីប្រាក់បៀវត្សរ៍។

RISE និង Mastercard ក៏បានសហការជាមួយ ILO’s Better Factories Cambodia និង TAFTAC ផងដែរ[១២] ដើម្បីធ្វើមាត្រដ្ឋានប្រាក់ឈ្នួលឌីជីថលប្រកបដោយការទទួលខុសត្រូវនៅទូទាំងរោងចក្រផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា។ របាយការណ៍នេះមាននិយាយអំពីការណែនាំសម្រាប់ម្ចាស់ម៉ាក អ្នកបញ្ជាទិញ អ្នកផ្តល់សេវាហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ដើម្បីគាំទ្រដល់ការពង្រីកវិសាលភាពការប្រើប្រាស់ប្រាក់ឈ្នួលឌីជីថល ដែលអាចនាំទៅរកភាពប្រសើរឡើងនូវការអនុវត្តសុខភាពហិរញ្ញវត្ថុសម្រាប់កម្មការនីនៅក្នុងវិស័យឧស្សាហកម្មនេះ។



# ប្រសិទ្ធភាពអាជីវកម្ម

## ការអនុវត្តប្រាក់ឈ្នួលឌីជីថល ផ្តល់ផលវិជ្ជមានក្នុងការបើកប្រាក់បៀវត្សរ៍ និងការសន្សំ



**៩៦%**

នៃកម្មករចង់អោយ
បើកប្រាក់ខែតាមគណនី

៩៦% នៃកម្មករទាំងបុរស និងស្ត្រី ពេញចិត្តក្នុងការបើកប្រាក់ខែតាមបែបឌីជីថល ដោយមានកំណើនកើនពី ៦២% កាលពីមុនពេលដាក់អោយប្រើប្រាស់កម្មវិធីការបើកប្រាក់ឈ្នួលឌីជីថលនេះ។ ហេតុផលសំខាន់ៗដែលបានលើកឡើងរួមមាន វាមានសុវត្ថិភាពជាងមុន ងាយស្រួលក្នុងការផ្ទេរប្រាក់ និងទិញទំនិញ។

**៨៤%**

បានកាត់បន្ថយលើថ្លៃចំណាយក្នុងកិច្ចការរដ្ឋបាល
ដែលសំដៅដល់ការចំណាយក្នុងការរៀបចំ និងដំណើរការបើកប្រាក់បៀវត្សរ៍



និយោជកបានរាយការណ៍ថា ពួកគេអាចសន្សំជាមធ្យម ១៦,០០០ ដុល្លារក្នុងមួយឆ្នាំលើថ្លៃចំណាយក្នុងដំណើរការបើកប្រាក់បៀវត្សរ៍តាមរយៈប្រាក់ឈ្នួលឌីជីថល។ អ្នកគ្រប់គ្រងចំណាយពេលប្រហែល ៤នាទី សំរាប់ការរៀបចំឯកសារអោយកម្មករម្នាក់ ក្នុងការដឹកជញ្ជូន រាប់ វេចខ្ចប់ និងចែកចាយប្រាក់ឈ្នួលជាសាច់ប្រាក់ ក្នុងមួយថ្ងៃបើកប្រាក់ខែ ហើយត្រូវបើក២ដងក្នុងមួយខែ[១៣].



កម្មករម្នាក់អាចចំនេញពេលផលិតកម្មរបស់ខ្លួនបានរហូតដល់៣៤នាទី ក្នុងមួយខែបន្ទាប់ពីបានអនុវត្តកម្មវិធី

**ប្រាក់ឈ្នួលឌីជីថល**

កម្មករម្នាក់ៗត្រូវខាតពេលក្នុងសង្វាក់ផលិតកម្មប្រហែល ១៧ នាទីក្នុងថ្ងៃបើកប្រាក់ខែ ២ដងក្នុងមួយខែ ដើម្បីបើកប្រាក់ឈ្នួលជាសាច់ប្រាក់សុទ្ធ។ សម្រាប់រោងចក្រជាមធ្យមដែលមានកម្មករ ១៥០០ នាក់ យើងអាចគណនាឃើញពីការសន្សំពេលវេលាផលិតបានប្រហែល ៨៥០ ម៉ោងជារៀងរាល់ខែ។

# ទិដ្ឋភាពម្ចាស់ម៉ាក

“នៅពេលដែលវាក្លាយជាកាតព្វកិច្ចក្នុងការបើកប្រាក់ឈ្នួលដល់កម្មករពីរដងក្នុងមួយខែ ពេលវេលាចំណាយលើការងាររដ្ឋបាលក្នុងការបើកប្រាក់ខែនឹងកើនឡើងយ៉ាងខ្លាំង។ ឥឡូវនេះយើងបានអនុវត្តការបើកប្រាក់ឈ្នួលឌីជីថល ហើយវាអាចជួយអោយការងារបញ្ចប់បានលឿនជាងមុន។ យើងសន្សំបាន ២-៣ ថ្ងៃក្នុងមួយខែ ក្នុងការចំណាយពេលដើម្បីបើកប្រាក់ខែអោយកម្មករ ហើយឥឡូវនេះកម្មករអាចសន្សំលុយ ទិញទំនិញតាមអ៊ីនធឺណិតឬអនឡាញ ផ្ទេរប្រាក់ បង់វិក័យបត្រ និងទិញធានារ៉ាប់រងសម្រាប់អនាគតកូនៗរបស់ពួកគេបានទៀតផង។”

លោក ឃិន ចំណាប់ មន្ត្រីប្រតិបត្តិតាម នៅក្រុមហ៊ុន Sun Hsu កម្ពុជា។



ការកំណត់បើកប្រាក់ឈ្នួលឌីជីថលក្នុងវិស័យកាត់ដេរនៅកម្ពុជា៖ អត្ថប្រយោជន៍សម្រាប់ស្ត្រី និងធុរកិច្ច - ព្រឹត្តិការណ៍អ្នកពាក់ព័ន្ធ ធ្វើឡើងក្នុងខែតុលា ឆ្នាំ២០២២ ដែលរៀបចំដោយស្ថាបនិក RISE HERproject និង Better Work; L-R លោក ឃិន ចំណាប់ មន្ត្រីប្រតិបត្តិតាម ក្រុមហ៊ុន Sun Hsu; លោក សោម ចាន់រតនាអតីតអ្នកគ្រប់គ្រងកម្មវិធីប្រព័ន្ធនិរន្តភាពនៅ Gap; លោកស្រី មាច សុជារី នាយកប្រតិបត្តិ CWPD; លោកស្រី Christine Svarer នាយកប្រតិបត្តិ RISE

## សេវាហិរញ្ញវត្ថុ

# កម្មករ និងកម្មការនី បានបង្កើនលទ្ធភាពក្នុងការទទួល និងប្រើប្រាស់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ

**៦៥%**
នៃការកើនឡើងរបស់កម្មករដែល
បានបើកប្រាក់ខែតាមគណនី

**៤២%**
បានកើនឡើងចំពោះស្ត្រីដែលចេះប្រើប្រាស់
ប្រតិបត្តិការហិរញ្ញវត្ថុដោយខ្លួនឯង

ការកើនឡើង
**២៤%**
នៃស្ត្រីក្នុងការចុះឈ្មោះស៊ីមកាតទូរស័ព្ទដោយប្រើ
ឈ្មោះរបស់ពួកគេផ្ទាល់។

**៥៥%**
បានកើនឡើង ចំពោះស្ត្រីដែលអាចធ្វើ
ប្រតិបត្តិការលុយតាមទូរស័ព្ទ

៩៨% នៃបុរសនិង ៩៩% នៃស្ត្រី បានបើកប្រាក់ខែតាមគណនីឌីជីថល កើនឡើងពី ៣៤% និង ៣៧% កាលពីមុនពេលប្រើប្រាស់កម្មវិធីប្រាក់ឈ្នួលឌីជីថលនេះ។[19] សម្រាប់កម្មករជាច្រើន នេះគឺជាគណនីហិរញ្ញវត្ថុដំបូងរបស់ពួកគេ។

៩៣% នៃស្ត្រីទាំងអស់បាននិយាយថា ពួកគេអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុដោយខ្លួនឯង ជាជាងពឹងផ្អែកលើសមាជិកគ្រួសារ មិត្តភ័ក្តិ ឬភ្នាក់ងារ ឬមិនដឹងពីរបៀបប្រើប្រាស់ ដែលកើនឡើងពី ៥១% កាលពីមុនប្រើប្រាស់កម្មវិធីប្រាក់ឈ្នួលឌីជីថលនេះ។ ទោះជាយ៉ាងណាក៏ដោយ កម្មករ ជាពិសេសស្ត្រីនៅតែចែករំលែកលេខកូដសម្ងាត់ ព័ត៌មានលំអិតរបស់ខ្លួនទៅអ្នកដទៃ (អាចចូលប្រើគណនីប្រាក់ចល័តរបស់ខ្លួនបាន)។

៨៨% នៃស្ត្រីបាននិយាយថាពួកគេមានទូរស័ព្ទទំនើបនៅពេលចាប់ផ្តើមកម្មវិធី ប៉ុន្តែមានតែ ៥៤% ប៉ុណ្ណោះដែលនិយាយថាពួកគេជាម្ចាស់ស៊ីមកាតទូរស័ព្ទដែលបានចុះឈ្មោះរបស់ពួកគេផ្ទាល់។ នៅចុងបញ្ចប់នៃកម្មវិធីនេះ ៩៩% នៃស្ត្រីបាននិយាយថាពួកគេជាម្ចាស់ទូរស័ព្ទទំនើប ហើយ ៧៨% នៃស្ត្រីបាននិយាយថាពួកគេមានស៊ីមកាតទូរស័ព្ទដែលបានចុះឈ្មោះដោយដាក់ឈ្មោះរបស់ពួកគេផ្ទាល់។

៩៨% នៃបុរស និង ៩៦% នៃស្ត្រី មានគណនីប្រាក់ចល័តដែលបានចុះឈ្មោះដោយប្រើប្រាស់ឈ្មោះរបស់ពួកគេផ្ទាល់ នៅចុងបញ្ចប់នៃកម្មវិធី ដោយមានការកើនឡើងពី ៤៥% និង ៤១% នៅពេលចាប់ផ្តើម។ បុរស និងស្ត្រីចំនួន ៦៦% បាននិយាយថា ពួកគេបានប្រើប្រាស់គណនីប្រាក់ចល័តដើម្បីទូទាត់ថ្លៃទំនិញ ៤១% បានផ្ទេរទៅឱ្យមិត្តភក្តិឬសមាជិកគ្រួសារ ២០% សម្រាប់ទិញកាតទូរស័ព្ទ និង ១៧% ដើម្បីបង់ថ្លៃអគ្គិសនី។



## ទស្សនរបស់កម្មករ

“ខ្ញុំចង់បើកប្រាក់ខែតាមគណនី [ជាងការបើកជាសាច់ប្រាក់សុទ្ធ]។ វាមានសុវត្ថិភាព និងងាយស្រួល។ ខ្ញុំអាចដកលុយបានគ្រប់ពេល បង់វិក្កយបត្រតាមអ៊ីនធឺណិត និងបញ្ចូលលុយទូរស័ព្ទ។ ខ្ញុំអាចប្រើ QRកូដ ដើម្បីទូទាត់ថ្លៃទិញទំនិញ។ ខ្ញុំធ្លាប់សន្សំលុយរបស់ខ្ញុំ[ជាសាច់ប្រាក់]នៅផ្ទះដោយដាក់ក្នុងទូ។ ឥឡូវនេះខ្ញុំនឹងទុកប្រាក់សន្សំរបស់ខ្ញុំនៅក្នុងគណនីសន្សំ។”

ខេម, កម្មករកាត់ដេរ, រាជធានីភ្នំពេញ, កម្ពុជា

## ការចំណាយ

# កម្មករបានផ្លាស់ប្តូររបៀបនៃការគ្រប់គ្រងការចំណាយរបស់ពួកគេ

មានការកើនឡើងចំនួន

**២៦%**

នៅក្នុងរបាយការណ៍ដែលស្ត្រីមាន **ទំនុកចិត្ត** ក្នុងការគ្រប់គ្រង **ការចំណាយរំពឹងទុក**

៩២%នៃស្ត្រីនិង ៩៣%នៃបុរស បាននិយាយថាពួកគេមានទំនុកចិត្តប្រសើរឬខ្លាំងជាងមុន ដោយកើនឡើងពី ៦៦% និង ៧២% មុនពេលការអនុវត្តកម្មវិធី។

មានការកើនឡើង

**៦៧%**

នៃចំនួនស្ត្រីក្នុង **ការតាមដានលើការចំណាយប្រចាំខែ** របស់ពួកគេ

៨០% នៃស្ត្រី និង ៦៨% នៃបុរសបានរាយការណ៍ថាបានតាមដានការចំណាយប្រចាំខែរបស់ពួកគេធៀបនឹង ១៣% និង ១៤% មុនពេលអនុវត្តកម្មវិធី។ នៅក្នុងប្រទេសកម្ពុជា វាជារឿងធម្មតាសម្រាប់ស្ត្រី ក្នុងការគ្រប់គ្រងថវិកាគ្រួសារសម្រាប់ការទិញរបស់របរតូចតាច ដូចជាគ្រឿងទេសជាដើម។

ការកើនឡើង

**១១%**

នៃចំនួនស្ត្រីក្នុងការ **សងប្រាក់កម្ចី** ត្រឹមត្រូវទាន់តាមកាលវិភាគ

៦២% នៃស្ត្រី និង ៥៣% នៃបុរស បានរាយការណ៍ថាពួកគេបានសងប្រាក់កម្ចី ដែលខ្ចីដោយពួកគេផ្ទាល់ឬគ្រួសាររបស់ពួកគេ ទាន់តាមកាលវិភាគបង់ប្រាក់ នេះបើប្រៀបធៀបទៅនឹង ៥១% និង ៥៤% មុនពេលអនុវត្តកម្មវិធី។ មូលហេតុចម្បងនៃការខ្ចីប្រាក់គឺដើម្បីទិញផ្ទះ អចលនទ្រព្យ ឬដី ឬបើកអាជីវកម្ម។ តាមរយៈរបាយការណ៍ដែលទទួលបាន កម្មករដែលរៀបការហើយ មានជាប់បំណុលប្រាក់កម្ចីជាងអ្នកមិនទាន់រៀបការ[១៥] ។

ការកើនឡើងនៃការសងប្រាក់កម្ចីត្រឹមត្រូវទាន់ទៅតាមកាលកំណត់នេះមានផលវិជ្ជមាន ប៉ុន្តែការសិក្សាមួយចំនួនបានបង្ហាញថា **ស្ត្រីមានទំនួលខុសត្រូវខ្ពស់ហួសពេកក្នុងការសងប្រាក់បំណុល** ដែលឈានដល់ការបាក់កំលាំងក្នុងការធ្វើការ។ ជាលទ្ធផល **ស្ត្រីបានកាត់បន្ថយការទទួលទានអាហាររបស់ពួកគេ** ដោយសារតែការកាត់បន្ថយប្រាក់ឈ្នួលពីការបិទរោងចក្រ ការព្យួរការងារ និងការកាត់ម៉ោងធ្វើការ ដែលនៅតែជារឿងធម្មតានៅក្នុងប្រទេសកម្ពុជា ក្រោយជំងឺកូវីដ១៩ ជាមួយនឹងការបញ្ជាទិញ ដែលមិនកំណត់ចំនួនច្បាស់លាស់ ឬថយចុះពីអ្នកបញ្ជាទិញ។

## ទស្សនរបស់កម្មករ

“ពេលនេះប្រាក់ខែរបស់ខ្ញុំមានសុវត្ថិភាពល្អណាស់នៅថ្ងៃបើកលុយ។ ខ្ញុំរក្សាទុកប្រាក់ខែរបស់ខ្ញុំនៅក្នុងគណនីរបស់ខ្ញុំរហូតដល់ខ្ញុំត្រូវចំណាយ។ ខ្ញុំក៏អាចប្រើគណនីរបស់ខ្ញុំដើម្បីបញ្ចូលលុយទូរស័ព្ទរបស់ខ្ញុំផងដែរ - វាមានប្រយោជន៍ច្រើនមែនទែន ដោយសាររោងចក្រនៅឆ្ងាយ [ពីគ្រួសារខ្ញុំ]។ ខ្ញុំក៏អាចផ្ញើលុយទៅផ្ទះបាន។ ខ្ញុំមិនមានប្រាក់កម្ចីទេ។ ខ្ញុំសន្សំទុកទិញដី និងគ្រឿងអលង្ការ។ ខ្ញុំរីករាយក្នុងការទទួលបានចំណេះដឹងពីការបណ្តុះបណ្តាល [RISE] និងអាចចែករំលែកជាមួយអ្នកដទៃទៀតផង។ វាមានប្រយោជន៍ណាស់ក្នុងការរៀនពីរបៀបប្រើលុយតាមទូរស័ព្ទ និងអាចបញ្ចូលលុយតាមទូរស័ព្ទបានទៀត។ ខ្ញុំបានប្រាប់អ្នកដែលខ្ញុំស្គាល់ប្រយ័ត្នប្រយែងជាមួយទូរស័ព្ទរបស់ពួកគេឥឡូវនេះ ព្រោះវាភ្ជាប់ទៅនឹងអត្តសញ្ញាណប័ណ្ណ/គណនីតាមទូរស័ព្ទរបស់ពួកគេ ។”

ហ៊ុយ, កម្មករកាត់ដេរ, រាជធានីភ្នំពេញ, កម្ពុជា។



# សុខភាពហិរញ្ញវត្ថុ

## កម្មករបានបង្កើនភាពរឹងមាំផ្នែកហិរញ្ញវត្ថុរបស់ពួកគេ

ស្ត្រីដែលរៀបការហើយភាគច្រើនរាយការណ៍ថា ពួកគេសន្សំលុយរៀងរាល់ខែឬច្រើនខែ ជាងស្ត្រីមិនទាន់រៀបការ។ គូស្វាមីភរិយាដែលរៀបការហើយ ច្រើនតែមានប្រាក់ចំណូលទ្វេរដង ដូច្នេះហើយជាធម្មតាមានលុយច្រើនដើម្បីអាចទុកមួយចំណែកក្នុងការសន្សំ។ ភាគច្រើនស្ត្រីដែលរៀបការរួចបានសន្សំសំចៃសម្រាប់ជាលុយបំរុងទុកក្នុងករណី ការចំណាយរំពឹងទុក និងក្នុងករណីមានគ្រោះអាសន្នដែលមិនបានរំពឹងទុក ចំណែកឯស្ត្រីនៅលីវភាគច្រើនសន្សំលុយដើម្បីទិញផ្ទះ។

**៣៨%**
កើនឡើងចំពោះស្ត្រីដែល
ចាប់ផ្ដើមអនុវត្តការសន្សំលុយជារៀងរាល់ខែ

៨៤% នៃស្ត្រីបានរាយការណ៍ពីការសន្សំលុយរៀងរាល់ខែ ឬ ច្រើនខែ កើនឡើងពី ៤៦% មុនពេល អនុវត្តកម្មវិធី។ ការកើនឡើងស្រដៀងគ្នានេះដែរក៏ត្រូវបានគេសង្កេតឃើញកើតឡើងចំពោះបុរសដែរ ក្នុងនោះ៧០% នៃកម្មករបុរស និងស្ត្រី ដែលសន្សំប្រាក់រៀងរាល់ខែ ឬច្រើនខែ សុទ្ធតែអ្នករៀបការហើយ។

ចំពោះស្ត្រីដែលមាន
**គណនីសន្សំ**
កើនឡើង
**៥៨%**

៨១% នៃស្ត្រី និង ៧៧% នៃបុរស រាយការណ៍ថាពួកគេមានគណនីដាច់ដោយឡែកសម្រាប់ការសន្សំរបស់ពួកគេ ដោយកើនឡើងពី ២៣% និង ២៤% រៀងគ្នានៅពេលចាប់ផ្ដើមកម្មវិធី។ ហើយនេះបានធ្វើអោយ កម្មករសន្សំលុយរបស់ពួកគេជាសាច់ប្រាកសុទ្ធតិចជាងមុន។ មានតែ ១៣% នៃស្ត្រីនិង ៩% នៃបុរសបានរាយការណ៍ពីការសន្សំលុយពួកគេជាសាច់ប្រាក់សុទ្ធ ដែលជាការថយចុះពី ៣៤% និង ២២% មុនពេលអនុវត្តកម្មវិធី។

ការកើនឡើង
**២៥%**
ចំពោះស្ត្រីដែល
សន្សំក្នុងគណនីធនាគារ

៥៤% នៃស្ត្រីបានរាយការណ៍ពីការសន្សំនៅក្នុងគណនីធនាគារកើនឡើងពី ២៩% មុនពេលអនុវត្តកម្មវិធី។ ២៣% នៃស្ត្រីដែលរាយការណ៍ពីការរក្សាទុកលុយពួកគេក្នុងគណនីប្រាក់ចល័ត បើប្រៀបធៀបទៅនឹង តួរលេខត្រឹមតែ ៣% មុនពេលអនុវត្តកម្មវិធី។ ៤៦% នៃស្ត្រីបានរាយការណ៍ពីការសន្សំលុយដើម្បីទុកប្រើប្រាស់ក្នុងករណីមានគ្រោះអាសន្នដែលមិនបានរំពឹងទុក ដោយតួរលេខនេះមានការកើនឡើងពី ១៩% មុនពេលអនុវត្តកម្មវិធី។ ការកើនឡើងក៏ត្រូវបានគេមើលឃើញផងដែរ សម្រាប់កម្មករដែលសន្សំលុយទុកដើម្បីធ្វើអាជីវកម្ម សម្រាប់ការចំណាយរំពឹងទុក ដូចជាការទិញផ្ទះ និងការចំណាយសម្រាប់ការអប់រំរបស់កុមារ។




## ទស្សនរបស់កម្មករ

“ខ្ញុំបានបើកលុយតាមគណនីធនាគារ ហើយខ្ញុំចូលចិត្តការបើកលុយបែបនេះ ជាងការបើកជាសាច់ប្រាក់សុទ្ធ។ [ការអនុវត្តតាមការបណ្តុះបណ្តាលសុខភាពហិរញ្ញវត្ថុ] ខ្ញុំបានរៀនប្រើគណនីរបស់ខ្ញុំដើម្បីទូទាត់ថ្លៃទិញទំនិញតាមអ៊ីនធឺណិត ហើយឥឡូវនេះខ្ញុំចេះទិញសម្លៀកបំពាក់អោយកូនខ្ញុំតាមអ៊ីនធឺណិត វាកាន់តែងាយស្រួល។

ខ្ញុំក៏បានចាប់ផ្តើមសន្សំ ១០ ដុល្លារក្នុងមួយខែ។ ខ្ញុំបាញ់លុយនេះ ទៅក្នុងគណនីសន្សំរបស់ខ្ញុំ។ ពីមុន ខ្ញុំសន្សំប្រាក់ដោយដាក់ក្នុងកូនជ្រូកក្នុងបន្ទប់របស់ខ្ញុំ ហើយពេលមួយនោះស្រមោចស៊ីក្រដាសប្រាក់ហ្នឹងអស់ខ្លះ អស់ប្រហែល ២៥ ដុល្លារ។ ខ្ញុំសន្សំសម្រាប់ការសិក្សារបស់កូនស្រីខ្ញុំ និងសម្រាប់ពេលមានអាសន្ន។ ម្យ៉ាងទៀតសម្រាប់អនាគតកូនក្រោយទៀតដែរ ប្រសិនបើខ្ញុំមានមួយទៀត។

ពេលទំនេរ ខ្ញុំទៅចំការរបស់ខ្ញុំដែលត្រូវចំណាយពេលជិះ ២ ម៉ោងពីទីនេះ [រោងចក្រ]។ ប្តីខ្ញុំមើលថែចំការ ហើយយើងដាំពោត ដំឡូងមី និងឪឡឹក។ ខ្ញុំចង់វិនិយោគលើដីចំការរបស់ខ្ញុំ និងទិញត្រាក់ទ័រ។

ឥឡូវនេះខ្ញុំកាន់តែមានទំនុកចិត្តលើការចំណាយនាពេលអនាគតរបស់ខ្ញុំ – ប្រសិនបើមាននរណាម្នាក់ឈឺ នោះខ្ញុំមានប្រាក់សន្សំដើម្បីបង់ថ្លៃមន្ទីរពេទ្យ”។

ចំប៉ី, កម្មការនីកាត់ដេរ, រាជធានីភ្នំពេញ, កម្ពុជា

## ការពង្រឹងសេដ្ឋកិច្ចរបស់ស្ត្រី

### ស្ត្រីមានការសំរេចចិត្តលើការចំណាយ និងការសន្សំ




ការកើនឡើង

**២៤%**

នៃស្ត្រីដែលធ្វើ

**ការសម្រេចចិត្តជាមួយគ្រួសាររបស់ពួកគេ**

ទាក់ទងនឹងការចំណាយ



ការកើនឡើង

**២៥%**

ក្នុងរបាយការណ៍ថាស្ត្រីមាន

**ទំនុកចិត្ត** ក្នុងការគ្រប់គ្រង

**ហិរញ្ញវត្ថុក្នុងភាពមានអាសន្ន**

៥៩% នៃស្ត្រីបាននិយាយថាពួកគេធ្វើការសម្រេចចិត្តជាមួយគ្រួសាររបស់ពួកគេបើប្រៀបធៀបទៅនឹង ៣៥% មុនពេលអនុវត្តកម្មវិធី។ ការផ្លាស់ប្តូរធ្វើការសម្រេចចិត្តជាមួយគ្រួសារជាជាងសម្រេចចិត្តតែម្នាក់ឯង គឺមានភាពវិជ្ជមានយ៉ាងខ្លាំងដែលបានបង្កើតទៅជាបទដ្ឋានប្រពៃណីនៅក្នុងប្រទេសកម្ពុជា។

៨០% នៃស្ត្រីបាននិយាយថាពួកគេមានទំនុកចិត្តខ្លះឬខ្លាំងជាងមុនបើប្រៀបធៀបទៅនឹង ៥៥% មុនពេលអនុវត្តកម្មវិធី។

## ហេតុអ្វីបានជាវាមានសារៈសំខាន់នៅក្នុងការប្រកាន់យកវិធីសាស្ត្រប្រកបដោយចេតនាយេនឌ័រ និងភាពប្រសព្វគ្នាក្នុងវិស័យកាត់ដេរកម្ពុជា?

នៅក្នុងប្រទេសកម្ពុជា ការអោយតំលៃលើបុរសជាងស្ត្រី និងបទដ្ឋានប្រពៃណីនៅក្នុងសង្គមនៅតែចាក់ឫសយ៉ាងជ្រៅ។[១៧] ស្ត្រីត្រូវបានគេរំពឹងថានឹងត្រូវធ្វើតាមស្វាមី ហើយមិនត្រូវបានលើកទឹកចិត្តឱ្យប្រព្រឹត្តស្មើភាពគ្នាចំពោះស្វាមីឡើយ។ បុរសត្រូវបានគេយល់ឃើញថាជាអ្នកធ្វើការសម្រេចចិត្តសំខាន់ក្នុងគ្រួសារ ហើយស្វាមីនៅកម្ពុជាមិនត្រូវបានលើកទឹកចិត្តឲ្យធ្វើតាមគំនិតផ្តួចផ្តើមឬការសម្រេចចិត្តរបស់ស្ត្រីឡើយ។[១៨] ស្ត្រីអាចគ្រប់គ្រងការចំណាយដូចជាការទិញគ្រឿងទេស ប៉ុន្តែបុរសត្រូវធ្វើការសម្រេចចិត្តលើការទិញរបស់មានតម្លៃថ្លៃៗដូចជាម៉ូតូជាដើម។

ឧស្សាហកម្មដែលមានភាពជាស្ត្រីខ្ពស់ទាមទារឱ្យអនុវត្តវិធីសាស្ត្រប្រកបដោយទំនោរយេនឌ័រ និងភាពប្រសព្វគ្នា ហើយត្រូវយកគិតគូរដល់ក្រុមមនុស្សក្នុងសង្គមដែលងាយរងគ្រោះបំផុត។ ចំនួនដ៏ច្រើននៃកម្មការនីក្នុង វិស័យកាត់ដេរនៅកម្ពុជា ផ្តល់ឱកាសពិសេសមួយដើម្បីបិទគម្លាតយេនឌ័រក្នុងការធ្វើបរិយាប័ន្នហិរញ្ញវត្ថុ តាមរយៈវិធីសាស្ត្រទំនោរយេនឌ័រ។

ការចូលរួមរបស់បុរសគឺមានសារៈសំខាន់ណាស់ក្នុងការពិចារណាលើឧបសគ្គដាក់លាក់របស់កម្មការនី និងបង្កើតកម្មវិធី និងផលិតផលសម្រាប់តម្រូវការរបស់ពួកគេ។ ការធ្វើឌីជីថលនីយកម្មប្រាក់ឈ្នួល ត្រូវតែដាក់រួមបញ្ចូលជាមួយការបណ្តុះបណ្តាលសមត្ថភាពហិរញ្ញវត្ថុ ដើម្បីជួយស្ត្រីឱ្យប្រើប្រាស់សេវាកម្ម និងដោះស្រាយបទដ្ឋានសង្គមជុំវិញការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ។ បើមិនដូច្នេះទេ ស្ត្រីអាចនឹងត្រូវបានគេឈប់គិតគូរមិនខាន។

# ទស្សនរបស់កម្មករ

“ខ្ញុំតែងតែពិភាក្សា និងចរចាជាមួយប្ដីរបស់ខ្ញុំ នៅពេលដែលយើងចង់ចំណាយលើអ្វីមួយ។ ឧទាហរណ៍ តើយើងនឹងចំណាយប៉ុន្មានលើការសិក្សារបស់កូន [ប៉ុន្តែ] ខ្ញុំមិនពិភាក្សាអំពីការចំណាយលើអាហារប្រចាំថ្ងៃជាមួយគាត់ទេ” ។

កម្មការនីកាត់ដេរ, រាជធានីភ្នំពេញ, កម្ពុជា



# អនុសាសន៍

RISE បានបង្ហាញឱ្យឃើញថា ប្រាក់ឈ្នួលឌីជីថលក្នុងវិស័យកាត់ដេរនៅកម្ពុជា អមជាមួយការបណ្តុះបណ្តាលសមត្ថភាពហិរញ្ញវត្ថុដោយទំនោរយេនឌ័រ អាចនាំទៅរកអត្ថប្រយោជន៍សម្រាប់ស្ត្រី និងអាជីវកម្ម។ កិច្ចសហការពីភាគីពាក់ព័ន្ធច្រើន ដែលគិតគូរពីតម្រូវការរបស់ស្ត្រី គឺជាគន្លឹះក្នុងការបង្កើននូវអត្ថប្រយោជន៍ទាំងនេះ។ ភាពជា ដៃគូផ្តល់នូវការណែនាំដូចខាងក្រោមសម្រាប់ម្ចាស់ម៉ាកល្បីៗក្នុងពិភពលោក អ្នកទិញ និងអ្នកផ្គត់ផ្គង់ អ្នកផ្តល់សេវាហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

## ភាគីពាក់ព័ន្ធទាំងអស់

- គាំទ្រដល់ការលើកកម្ពស់ការធ្វើអនុវត្តប្រាក់ឈ្នួលឌីជីថលផ្អែកលើចេតនាយេនឌ័រ និងជំរុញការដាក់បញ្ចូលហិរញ្ញវត្ថុ និងការពង្រឹងសេដ្ឋកិច្ចរបស់កម្មករ។
- លើកទឹកចិត្តភាគីពាក់ព័ន្ធ សំខាន់ៗចូលរួមជាមួយការបង្កើតករណីអាជីវកម្មដើម្បីបង្ហាញថាតើការការអនុវត្ត ប្រាក់ឈ្នួលឌីជីថលផ្អែក លើចេតនាយេនឌ័រ អាចជួយពួកគេឱ្យសម្រេចបាននូវគោលដៅនៃអាជីវកម្មបានដោយរបៀបណា

## ម្ចាស់ម៉ាក/អ្នកផ្គត់ផ្គង់

- គាំទ្រដល់ការបណ្តុះបណ្តាលសមត្ថភាពហិរញ្ញវត្ថុដោយចេតនាយេនឌ័រសម្រាប់កម្មករនិយោជិតដើម្បីធ្វើការពង្រឹងសុខភាពហិរញ្ញវត្ថុរបស់ពួកគេ និងដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញពីការធ្វើឌីជីថលប្រាក់ឈ្នួល
- ត្រូវប្រាកដថាការចំណាយលើប្រាក់ឈ្នួលឌីជីថលមិនត្រូវបានកាត់ពីប្រាក់ខែរបស់កម្មករនោះទេ ហើយកម្មករអាចដកប្រាក់ខែរបស់ពួកគេដោយមិនមានកាត់ថ្លៃសេវាកម្ម

## អ្នកផ្តល់សេវាហិរញ្ញវត្ថុ

- ជំរុញការធ្វើមាត្រដ្ឋាននៃការទទួលយកពាណិជ្ជករដើម្បីបង្កើនឱកាសក្នុងការប្រើប្រាស់ការទូទាត់បែប ឌីជីថល និងលទ្ធភាពពាណិជ្ជកម្មនៃគណនីបើកប្រាក់បៀវត្សរ៍
- គាំទ្រការអភិវឌ្ឍន៍ផលិតផលហិរញ្ញវត្ថុបន្ថែមទៀតដើម្បីបង្កើនការសន្សំប្រាក់របស់កម្មករ

## អ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត

- ធានាឱ្យបាននូវសម្ភារៈបណ្តុះបណ្តាលសមត្ថភាពហិរញ្ញវត្ថុដោយគិតពីតម្រូវការរបស់ស្ត្រី និងដោះស្រាយបទដ្ឋានយេនឌ័រ និងសក្តានុពលនៃថាមពលដែលមានឥទ្ធិពលលើការសម្រេចចិត្តក្នុងគ្រួសារ និងសហគមន៍។
- លើកកម្ពស់ការបណ្តុះបណ្តាលអំពីយេនឌ័រ ដោយការកសាងសមត្ថភាពគ្រូបណ្តុះបណ្តាលស្តីពីការដោះស្រាយបទដ្ឋានយេនឌ័រ តម្រូវការហិរញ្ញវត្ថុ និងឧបសគ្គរបស់ស្ត្រី និងបុរស និងប្រើប្រាស់វិធីសាស្ត្របណ្តុះបណ្តាលដោយមានបញ្ជ្រាបពីយេនឌ័រ។

## ទិដ្ឋភាពម្ចាស់ម៉ាក

“ការអនុវត្តប្រាក់ឈ្នួលឌីជីថលអាចចំណាយពេលច្រើន ប៉ុន្តែអត្ថប្រយោជន៍សម្រាប់ទាំងអ្នកជំនួញ និងកម្មករគឺត្រូវបានមើលឃើញយ៉ាងជាក់លាក់។ មានសារៈសំខាន់ខ្លាំងណាស់ក្នុងការធានាថាអ្នកគ្រប់គ្រងរោងចក្រយល់ពី ផលចំណេញនៃការអនុវត្តប្រាក់ឈ្នួលឌីជីថល និងត្រូវប្រាកដថាកម្មករទទួលបានការគាំទ្រយ៉ាងពេញលេញ និងទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវតាមរយៈដំណើរការនៃការអនុវត្តនេះ។ យើងរីករាយក្នុងការលើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកផ្គត់ផ្គង់របស់យើង និងចែករំលែកចំណេះដឹងនេះជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត”

លោកស្រី យុន សុខា អ្នកឯកទេសជាន់ខ្ពស់ផ្នែកទំនួលខុសត្រូវសង្គមសាជីវកម្ម ក្រុមហ៊ុន Carter’s, Inc.



ធនធាន

# ប្រាក់ឈ្នួលឌីជីថល និងធនធានសមត្ថភាពហិរញ្ញវត្ថុ

ធនធានខាងក្រោមត្រូវបានបង្កើតឡើងដោយ RISE ជាមួយ Mastercard គឺអាចរកបានយ៉ាងងាយស្រួលតាមអ៊ីនធឺណិត៖

## ឧបករណ៍ឌីជីថលប្រាក់ឈ្នួលសម្រាប់និយោជក

កំណត់ការអនុវត្តដែលល្អ និងការណែនាំ សម្រាប់អ្នកគ្រប់គ្រងក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកការបើកប្រាក់ឈ្នួលឌីជីថលប្រកបដោយទំនួលខុសត្រូវ និងមានប្រសិទ្ធភាព។ អាចរកបានតាមអ៊ីនធឺណិតជាភាសាខ្មែរនិងអង់គ្លេស។ សម្រាប់ការចូលទៅប្រើប្រាស់ក្រៅបណ្តាញ អាចទាញយកបានពី Google Playstore ។




## ការណែនាំសម្រាប់ម្ចាស់ម៉ាក និងអ្នកបញ្ជាទិញ

មគ្គុទ្ទេសក៍នេះផ្តល់ជូនម្ចាស់ម៉ាកនិងអ្នកបញ្ជាទិញ នូវជំហានជាក់ស្តែង និងបែងចែកជា ៤ ដំណាក់កាល សម្រាប់ការធានានូវប្រាក់ឈ្នួលឌីជីថលប្រកបដោយនិរន្តរភាព ដែលផ្តល់អត្ថប្រយោជន៍ទាំងអាជីវកម្ម និងកម្មករ។

## ការណែនាំសម្រាប់អ្នកផ្តល់សេវាហិរញ្ញវត្ថុ

បង្កើតឡើងដោយ Mastercard ការណែនាំនេះផ្តល់ជូនអ្នកផ្តល់សេវាហិរញ្ញវត្ថុ នូវជំហានជាក់ស្តែង ដើម្បីបង្កើតផ្នែកប្រាក់ឈ្នួលឌីជីថល រួមទាំងការទិញយក ការជំរុញការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងការរក្សាអតិថិជនថ្មី។

## វីដេអូសុខភាពហិរញ្ញវត្ថុ RISE

កញ្ចប់វីដេអូ និងគំនូរជីវចលចំនួន ៦ ដែលបង្កើតឡើងដោយ QuizRR អាចយកមកប្រើប្រាស់បានក្នុងកំឡុងពេលធ្វើការបណ្តុះបណ្តាល ឬចាក់មើលដោយខ្លួនឯង ដូចជាចាក់នៅក្នុងអាហារដ្ឋានក្នុងរោងចក្រជាដើម។ បញ្ជីវីដេអូជាភាសាខ្មែរ។

## មេរៀនសិក្សាអំពីប្រាក់ឈ្នួលឌីជីថលសម្រាប់កម្មករ

បង្កើតឡើងដោយសហការជាមួយ QuizRR ប្រើប្រាស់ក្នុងរូបភាពជា ភាពយន្ត កម្រងសំណួរ និងគំនូរជីវចល ដែលចូលរួមគាំទ្រដល់កម្មករដើម្បីបង្កើនចំណេះដឹងរបស់ពួកគេអំពីសេវាកម្មហិរញ្ញវត្ថុ ការពង្រឹងសុខភាពហិរញ្ញវត្ថុ និងកសាងចំណេះដឹងឌីជីថលរបស់ពួកគេ។ អាចយកមកប្រើប្រាស់បានតាមអនឡាញជាភាសាខ្មែរ។

## សារ RISE ជាសំឡេង

សារជាសំឡេងចំនួន ៥ អំពីសេវាកម្មហិរញ្ញវត្ថុ និងការគ្រប់គ្រងប្រាក់ អាចប្រើប្រាស់បានជាភាសាខ្មែរ។

## ផ្ទាំងរូបភាពសុខភាពហិរញ្ញវត្ថុ RISE

កញ្ចប់នៃផ្ទាំងរូបភាពចំនួន៦ ដែលបង្ហាញព័ត៌មានអំពីសេវាកម្មហិរញ្ញវត្ថុ និងការគ្រប់គ្រង។ អាចយកមកប្រើប្រាស់បានតាមអនឡាញជាភាសាខ្មែរ។



# ឯកសារយោង


1. ILO Cambodia Garment and Footwear Sector Bulletin Issue 8, ILO, December 2018
2. The Global Findex Database 2021: Financial Inclusion, Digital Payments and Resilience in the Age of COVID-19; World Bank Group, June 2023
3. 'Worn out': debt discipline, hunger, and the gendered contingencies of the COVID-19 pandemic amongst Cambodian garment workers Katherine Brickell, Sabina Lawreniuk, Theavy Chhom, Reach Mony, Hengvotey So & Lauren McCarthy (2023), Social & Cultural Geography, 24:3-4, 600-619
4. Over-Indebtedness in Cambodia: Findings from a Financial Diaries Study, Microfinance Opportunities, 2017
5. Financial Health គិតគូរពីរបៀបដែលមនុស្សម្នាក់គ្រប់គ្រងហិរញ្ញវត្ថុ និងចំណាប់អារម្មណ៍របស់ពួកគេទាក់ទងនឹងលុយ។ វាគឺជារង្វាស់នៃសមត្ថភាពរបស់មនុស្សម្នាក់ក្នុងការគ្រប់គ្រងការចំណាយ បន្តគោលដៅហិរញ្ញវត្ថុ និងភាពរឹងមាំរបស់ពួកគេចំពោះវិបត្តិហិរញ្ញវត្ថុដែលជះឥទ្ធិពលដល់សុខុមាលភាពហិរញ្ញវត្ថុ។
6. Brief: Promoting responsible digital wage payments – Digital Wages. ILO, March 2023
7. The Potential Gains of Digitizing Garment Sector Wages in Cambodia HERproject, IFC, under the IFC/ILO Better Work, August 2022
8. Navigating wage digitization: A rapid qualitative review of garment workers' experience in Cambodia – Digital Wages ILO, August 2023
9. Big potential for digitizing wage payments in Cambodia's garment factories IFC blog by Leora Klapper, Maria Soledad Requejo, and Christine Svarer, December 2021
10. Building Women's Financial Capability: A Path Toward Transformation Center for Financial Inclusion, June 2021
11. ការស្ទង់មតិកម្មករ RISE បានធ្វើឡើងនៅចន្លោះខែកញ្ញា ឆ្នាំ 2021 ដល់ខែកុម្ភៈ ឆ្នាំ 2023 ជាមួយនឹងកម្មករចំនួន 451 នាក់ (ស្ត្រី 240 នាក់ និងបុរស 211 នាក់) មកពីរោងចក្រចំនួន 9 មុនការអនុវត្តកម្មវិធី និងកម្មករចំនួន 402 នាក់ (ស្ត្រី 203 នាក់ និងបុរស 199 នាក់) មកពីរោងចក្រចំនួន 8 បន្ទាប់ពីការអនុវត្តកម្មវិធី។ នៅពេលចាប់ផ្តើមកម្មវិធី រោងចក្រចំនួន 3 បានបើកប្រាក់ខែបែបឌីជីថល និង 6 បើកប្រាក់ខែជាសាច់ប្រាក់។ នៅចុងបញ្ចប់នៃកម្មវិធី រោងចក្រទាំងអស់បានធ្វើការប្តូរមកបើកប្រាក់ខែបុគ្គលិកតាមបែបឌីជីថលវិញ។
12. Textile, Apparel, Footwear and Travel Goods Association - TAFTAC (taftac-cambodia.org)
13. ឧបករណ៍វិភាគអត្ថប្រយោជន៍អាជីវកម្ម RISE បានបញ្ចប់ដោយការចូលរួមពីរោងចក្រកាត់ដេរចំនួន 8។
14. សូមមើលយោងលេខ 11
15. នេះរាប់បញ្ចូលទាំងបុរស និងស្ត្រី ដែលអាចនឹងមិនទាន់រៀបការ, នៅលីវ ដោយមានឬគ្មានដៃគូ, បែកគ្នា, លែងលះគ្នា ឬស្ត្រីមេម៉ាយ។
16. សូមមើលឯកសារយោងលេខ 3
17. 'I know I cannot quit.' The Prevalence and Productivity Cost of Sexual Harassment to the Cambodian Garment Industry CARE International, March 2017
18. ការពិនិត្យឡើងវិញអំពីយេនឌ័រនៃ Cambodia Transform Financial Health ត្រូវបានរៀបចំដោយ RISE និងអនុវត្តដោយ សុធារី យូ អ្នកប្រឹក្សាសមភាពយេនឌ័រ និងការដាក់បញ្ចូលសង្គមនៅក្នុងខែមេសា ឆ្នាំ 2023


## ការទទួលស្គាល់

ក្រេឌីតរូបភាព៖ RISE; និង BSR/Jean Francois Perigois


សូមអរគុណដល់ដៃគូរបស់យើងមានដូចជា Better Factories Cambodia, CWPD, Carters, GAP, ILO, Inditex, PVH, Ralph Lauren, Target, The Children's Place, ស្ថាបនិករបស់យើងមានដូចជា Mastercard Impact Fund និងដោយមានការគាំទ្រពី Mastercard Center for Inclusive Growth និងសូមអរគុណដល់អ្នកគ្រប់គ្រង និង កម្មករកាត់ដេរ ដែលបានចែករំលែកបទពិសោធន៍ និងមតិកែលម្អរបស់ពួកគេជាមួយយើង។

របាយការណ៍នេះត្រូវបានបង្កើតឡើងដោយ Charlotte Pallangyo, Sethypong Sok, Ella Moffat និង Christine Svarer ពី RISE ដោយមានការចូលរួមពី Virak Nuon ពី Better Factories Cambodia។ ការបកប្រែជាភាសាខ្មែរត្រូវបានធ្វើឡើងដោយ CWPD ។


Center for Inclusive Growth

Mastercard Center for Inclusive Growth ជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងនិរន្តរភាព និងការដាក់បញ្ចូលបរិយាប័ន្នហិរញ្ញវត្ថុជុំវិញពិភពលោក។ ខណៈពេលដែលរៀបចំចាត់ចែងកម្មវិធីសប្បុរសធម៌ Mastercard Impact Fund មជ្ឈមណ្ឌលប្រើប្រាស់ធនធាន និងសមត្ថភាពស្នូលរបស់ក្រុមហ៊ុនរួមទាំងការយល់ដឹងអំពីទិន្នន័យ ជំនាញ និងបច្ចេកវិទ្យា ដើម្បីផលិតការស្រាវជ្រាវឯករាជ្យ ធ្វើមាត្រដ្ឋានកម្មវិធីជាសកល និងផ្តល់សិទ្ធិអំណាចដល់សហគមន៍អ្នកគិត អ្នកដឹកនាំ និងអ្នកធ្វើអោយឈរនៅលើខ្សែបន្ទាត់ជួរមុខនៃកំណើនប្រកបដោយស្មេរភាព។ សម្រាប់ព័ត៌មានបន្ថែម និងដើម្បីទទួលជ្រាបពីវឌ្ឍនភាពចុងក្រោយរបស់យើង សូមតាមដានអំពីមជ្ឈមណ្ឌលតាមរយៈLinkedIn, Instagram និង subscribe ព្រឹត្តិប័ត្រព័ត៌មាន

www.mastercardcenter.org

RISE: Reimagining Industry to Support Equality គឺជាគំនិតផ្តួចផ្តើមមួយដើម្បីគាំទ្រដល់សកម្មភាពឧស្សាហកម្មរួមគ្នាក្នុងកម្រិតមួយ ដើម្បីជំរុញសមភាពយេនឌ័រនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សម្លៀកបំពាក់ ស្បែកជើង និងវាយនភណ្ឌ។ RISE នាំមកជូននូវកម្មវិធីផ្តល់សិទ្ធិអំណាចស្ត្រីធំបំផុតចំនួន ៤ របស់ឧស្សាហកម្មម៉ូដសំលៀកបំពាក់ពីគម្រោង BSR's HERProject, GAP Inc. P.A.C.E, CARE និង Better Work ជាមួយនឹងបទពិសោធន៍ជាង១៥ឆ្នាំនៃការអនុវត្តកម្មវិធីពង្រឹងសិទ្ធិអំណាចរបស់ស្ត្រីនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សកលដើម្បីបង្កើតឡើងដោយប្រើវិធីសាស្ត្របង្ហាញអោយឃើញ។ RISE ផ្តោតលើអាទិភាពដែលទាក់ទងគ្នាចំនួន៣ ជាមួយនឹងសក្តានុពលក្នុងការបង្កើតការផ្លាស់ប្តូរនៃភាពរីកចំរើនក្នុងជីវិតរបស់កម្មការនី និងគាំទ្រដល់លទ្ធផលអាជីវកម្មដែលប្រសើរឡើង រួមទាំងសុខភាពហិរញ្ញវត្ថុ ការទប់ស្កាត់អំពើហិង្សា ការបៀតបៀនយេនឌ័រ ការរីកចំរើននឹងភាពជាអ្នកដឹកនាំរបស់ស្ត្រី។

riseequal.org